

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

គោលនយោបាយ

អប់រំបំណិនជីវិត

២០០៦



អប់រំបំណិនជីវិត

២០០៦

អារម្ភបទ

វិស័យអប់រំជាវិស័យគន្លឹះរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ វិស័យនេះបានត្រូវចាត់ទុកជាវិស័យ អាទិភាពមួយ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ដើម្បីសម្រេចអាទិភាពនេះ ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យឡើងវិញដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ នៅខែធ្នូ ឆ្នាំ ២០០៥ កម្មវិធីគាំទ្រវិស័យអប់រំ ២០០៦-២០១០ នៅខែធ្នូ ឆ្នាំ ២០០៥ និងបានប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយសំរាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ នៅខែធ្នូ ឆ្នាំ ២០០៤។

គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ ជាលទ្ធផលនៃការកែលំអ និងពិនិត្យឡើងវិញនូវកម្មវិធីសិក្សាបច្ចុប្បន្ន ។ ចំណុចជាច្រើនបានត្រូវបញ្ចូលទៅក្នុងគោលនយោបាយថ្មីនេះមាន ជាអាទិការផ្តល់ការអប់រំបំណិនជីវិតក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ការផ្តល់សិទ្ធិអោយសិស្សជ្រើសរើសមុខវិជ្ជាសិក្សានៅកំរិតមធ្យមសិក្សាទុតិយភូមិ និងការកំណត់ស្តង់ដាកម្មវិធីសិក្សានៅកម្រិតអប់រំចំណេះទូទៅ។

បន្ទាប់ពីបានបញ្ចប់គោលនយោបាយសំរាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ ដោយជោគជ័យមក ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយអប់រំបំណិនជីវិត ២០០៦ ដើម្បីជួយបំពេញអោយគោលនយោបាយសំរាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ គោលនយោបាយអប់រំក្រៅប្រព័ន្ធឆ្នាំ២០០២ និងឆ្លើយតបទៅនឹងតម្រូវការនានាក្នុងបរិបទសកលភាវូបនីយកម្ម និងតំបន់នីយកម្ម។

ក្រសួងអប់រំ យុវជន និងកីឡាមានជំនឿថា គោលនយោបាយអប់រំបំណិនជីវិត ២០០៦ ជាឯកសារចាំបាច់ដ៏មានសារៈសំខាន់សំរាប់អ្នកគ្រូ លោកគ្រូ សាលារៀន គ្រឹះស្ថានសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ សហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ មន្ត្រីអប់រំ មាតាបិតាសិស្ស អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងអ្នកចាប់អារម្មណ៍នានា ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា គ្រប់សាលារៀនក្នុង និងក្រៅប្រព័ន្ធ សហគមន៍មូលដ្ឋាន អង្គការនានា និងអ្នកចាប់អារម្មណ៍ទាំងអស់នឹងសហការគ្នាជួយគាំទ្រការអនុវត្តគោលនយោបាយនេះអោយបានជោគជ័យដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម វប្បធម៌ និងសេដ្ឋកិច្ចកម្ពុជា។

មាតិកា

អារម្ភបទ ១

១. សេចក្តីផ្តើម ៤

២. និយមន័យ ៦

៣. គោលបំណង ៧

៤. ខ្លឹមសារ ៨

៥. យុទ្ធសាស្ត្រ ១០

៦. វិធីសាស្ត្រ ១១

៧. ការណែនាំអនុវត្ត ១៣

អវសានបទ ១៨

១. សេចក្តីផ្តើម

១.១ ប្រទេសជាច្រើនលើសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្រៀនបំណិនជីវិត ដើម្បីអោយអ្នកសិក្សាមានចំណេះដឹង បំណិនអភិវឌ្ឍខ្លួនដើម្បីក្លាយជាមនុស្សល្អ និងចេះរស់នៅជាមួយគ្នា។ ការអប់រំបំណិនជីវិតបានត្រូវចាត់ទុកថា ជាកម្មវិធីអប់រំសំខាន់មួយដែលសាលារៀនក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធត្រូវយកចិត្តទុកដាក់ចូលរួមយ៉ាងសកម្ម។

១.២ ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-១៥ ក្នុងចំណុចទី៦ បានចែងថា"...កែលំអគ្រប់ទិដ្ឋភាពនៃគុណភាពអប់រំ និងធានាបាននូវគុណភាពប្រសើរបំផុតគ្រប់ផ្នែក ដើម្បីអោយមនុស្សគ្រប់រូបដណ្តើមបាន លទ្ធផលរៀនសូត្រមានកម្រិតវាស់បាន មានការទទួលស្គាល់ ជាពិសេសផ្នែកភាសាខ្មែរ លេខនព្វន្ត និងជំនាញចាំបាច់សម្រាប់ចិញ្ចឹមជីវិត (បំណិនជីវិត) (ទំព័រទី៦៤)។

១.៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-១០ បានចែងថា "...អនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មី ទាំងនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយផ្តោតលើស្តង់ដាកម្មវិធីសិក្សានៅថ្នាក់ទី ៣-៦ និង ទី៩ និងដាក់អោយអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន..." (ទំព័រទី២០)។

១.៤ នៅខែធ្នូឆ្នាំ២០០៤ ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-០៩។ គោលនយោបាយថ្មីនេះបានយកចិត្តទុកដាក់ដល់ការអប់រំបំណិនជីវិតដែលផ្តល់អោយសិស្សនូវបំណិនជីវិតទូទៅក្នុងកម្មវិធីសិក្សាជាតិ និងបំណិនជីវិតតាម

មូលដ្ឋាន។ គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ បានកំណត់ថា "សាលារៀនត្រូវបង្កើនភាពជាដៃគូជាមួយមាតាបិតា សហគមន៍មូលដ្ឋានអង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ហើយត្រូវអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលមានពី ២ ទៅ ៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍ មួយម៉ោងសិក្សាមានរយៈពេល ៤០ នាទីសម្រាប់បឋមសិក្សា និង ៥០ នាទី សម្រាប់មធ្យមសិក្សាដើម្បីជួយបំពេញកម្មវិធីសិក្សាជាតិ" (ទំព័រទី៤)។

១.៥ ឆ្លើយតបទៅនឹងខ្លឹមសារដែលបានចែងខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយអប់រំបំណិនជីវិត ២០០៦។ គោលនយោបាយនេះជាការកែលំអឡើងវិញ និងជាការអភិវឌ្ឍបន្ថែមនូវគោលនយោបាយអប់រំបំណិនជីវិតសម្រាប់សាលារៀនចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតឡើងក្នុងខែសីហា ឆ្នាំ២០០១ ។ គោលនយោបាយអប់រំបំណិនជីវិតថ្មីនេះអាចអនុវត្តបានទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ៤

២. និយមន័យ

២.១ ក្នុងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥ -២០០៩ បំណិនជីវិតត្រូវបានកំណត់ថាជា បំណិនបញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព ។

២.២ ឯកសារគោលនយោបាយអប់រំបំណិនជីវិតបានកំណត់បំណិនជីវិតជាពីរប្រភេទ :

■ បំណិនមូលដ្ឋាន

បំណិនមូលដ្ឋាន ជាបំណិនចាំបាច់ដែលអ្នកសិក្សាគ្រប់រូបត្រូវតែទទួលបានដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ការរស់នៅ។ បំណិនមូលដ្ឋានមាន :

- **បំណិនជីវិតទូទៅ** មានសុខភាពផ្ទាល់ខ្លួន សុវត្ថិភាព ការធ្វើផែនការសម្រាប់ជីវភាពប្រចាំថ្ងៃ ការរៀបចំចាត់ចែង ការធ្វើទំនាក់ទំនង និងភាពជាពលរដ្ឋពេញលេញ និងមានសីលធម៌រស់នៅថ្លៃថ្នូរ ។

- **បំណិនបុរេវិជ្ជាជីវៈ** សម្រាប់អោយអ្នកសិក្សាចូលរួមក្នុងការងារពលកម្ម ឬសហគមន៍របស់គេ បំណិនក្នុងការធ្វើទំនាក់ទំនង បំណិនគណិតវិទ្យា បំណិនក្នុងការដោះស្រាយបញ្ហា និងបំណិនក្នុងការចេះធ្វើការងារជាក្រុម ។

បំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជាជីវៈត្រូវបានចាត់ទុកថា ជាបំណិនមូលដ្ឋានសម្រាប់ពលរដ្ឋទាំងអស់ ។

■ បំណិនអាជីព

បំណិនអាជីព ជាបំណិនដែលសិស្សអាចជ្រើសរើសសិក្សា ដើម្បីជាសញ្ញាណវិជ្ជាជីវៈមូលដ្ឋានសម្រាប់ឈានទៅដល់អាជីពមួយច្បាស់លាស់នាពេលអនាគត។ បំណិនអាជីពមាន :

- **បំណិនអាជីពងាយ** ជាបំណិនដែលទាក់ទងនឹងមុខជំនាញសាមញ្ញ ដោយត្រូវការការបណ្តុះបណ្តាល រយៈពេលខ្លី និងបច្ចេកទេសងាយៗសម្រាប់អ្នកសិក្សាមានលទ្ធភាពលើកកំពស់ជីវភាព ឬបង្កើនសេដ្ឋកិច្ចគ្រួសារ។ អ្នកសិក្សាម្នាក់ៗអាចអភិវឌ្ឍបំណិនអាជីពងាយមិនដូចគ្នាទេ អាស្រ័យលើធនធានតម្រូវការតាមមូលដ្ឋាន និងចំណង់ចំណូលចិត្តរបស់គេផ្ទាល់។

- **បំណិនវិជ្ជាជីវៈ** ជាបំណិនដែលទាក់ទងទៅនឹងមុខជំនាញឯកទេសដោយត្រូវការការបណ្តុះបណ្តាល រយៈពេលមធ្យម ឬវែង និងជំនាញបច្ចេកទេសកម្រិតខ្ពស់សម្រាប់អ្នកសិក្សាធ្វើជាទុនក្នុងការប្រកបមុខរបរនានាដើម្បីចិញ្ចឹមជីវិត។

៣. គោលបំណង

គោលបំណងនៃការអប់រំបំណិនជីវិត គឺអោយអ្នកសិក្សាទាំងពីរភេទ ស្រី និងប្រុស មានឱកាសស្មើគ្នាក្នុងការទទួលបានការសិក្សាផ្នែកចំណេះដឹង ជំនាញ និងការចូលរួមក្នុងជីវភាពសង្គម។ អ្នកសិក្សានឹងមាន :

- បំណិនមូលដ្ឋានផ្នែកអក្សរសាស្ត្រ ផ្នែកគណនាលេខ និងបំណិនក្នុងការសិក្សាពេញមួយជីវិត ដែលធ្វើអោយពួកគេមានសមត្ថភាពក្នុងការធ្វើទំនាក់ទំនង ការស្វែងរកពត៌មាន និងការផ្លាស់ប្តូរគំនិតក្នុងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព។

- ចំណេះដឹង បំណិន និងឥរិយាបថចាំបាច់ដើម្បីបង្កើនសុខភាពផ្ទាល់ខ្លួន បំណិនលំហែកំសាន្ត និងការរួមចំណែកក្នុងការធ្វើអោយមានសុខុមាលភាពក្នុងគ្រួសារ ចូលរួមធ្វើពលកម្មក្នុងសាលារៀន និងសហគមន៍ ។

- បំណិនថ្មៃប្រឌិតប្រកបដោយប្រសិទ្ធភាព មានសមត្ថភាពក្នុងការគិតពិចារណាដោយម្ចាស់ការ ចេះផ្តល់គំនិតយោបល់ ចេះបត់បែនទន់ភ្លន់តាមកាលៈទេសៈ ចេះធ្វើការងារជាមួយគ្នា ចេះរស់នៅជាមួយគ្នា ចេះយោគយល់គ្នា ចេះធ្វើការសម្រេចចិត្ត ចេះរៀបចំសកម្មភាពផ្សេងៗ ចេះរៀបចំផែនការគ្រួសារ និងចេះកសាងខ្លួនអោយក្លាយជាមនុស្សស្រឡាញ់ការងារ ។

- បំណិនអនុវត្តវិជ្ជាជីវៈស្របតាមធនធាន និងតម្រូវការក្នុងមូលដ្ឋាន ព្រមទាំងចំណង់ចំណូលចិត្តរបស់ខ្លួន ដើម្បីបង្កើនគុណភាពជីវិតរស់នៅ ។

៥. ខ្លឹមសារ

៥.១ បំណិនមូលដ្ឋាន ត្រូវបង្រៀនដល់អ្នកសិក្សាទាំងអស់ ព្រោះវាជាផ្នែកមួយនៃកម្មវិធីសិក្សាជាតិកម្រិតអប់រំមូលដ្ឋានចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធដែលទាក់ទងនឹងប្រធានបទសំខាន់ៗ : ៤

- ការអប់រំសុខភាព សុវត្ថិភាព អាហារូបត្ថម្ភ លំហែកំសាន្ត ការបង្ការជំងឺ វិធីផ្សេងៗដែលធ្វើអោយមានសុខភាពល្អ (អនាម័យចំណីអាហារ...) សុវត្ថិភាពចរាចរណ៍ យល់ដឹងពីគ្រោះថ្នាក់នៃការលង់ទឹក យល់ដឹងពីគ្រោះថ្នាក់នៃគ្រាប់មីន យល់ដឹងពីមេរោគអេច អាយ វី (HIV) ជំងឺអេដស៍ (AIDS) គ្រោះថ្នាក់នៃគ្រឿងញៀន ផ្តាសាយបក្សី ល្បែងពាលា ការការពារបរិស្ថាន...។

- ការអភិវឌ្ឍបុគ្គល មានការកសាងខ្លួន ការចេះអោយតម្លៃខ្លួនឯង បំណិនធ្វើការងារជាក្រុម ការចេះរស់នៅជាមួយគ្នាដោយសុខដុម ការដោះស្រាយបញ្ហាចំពោះមុខដោយសន្តិវិធី...។

- ការអប់រំអោយក្លាយជាប្រជាពលរដ្ឋល្អ ដែលមានចំណេះដឹងពីជីវភាពសហគមន៍ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស សិទ្ធិកុមារ យេនឌ័រ ទំនាក់ទំនងក្នុងសង្គម ច្បាប់ ទំនៀមទំលាប់ប្រពៃណីជាតិ និងមានការទទួលខុសត្រូវចំពោះបរិស្ថាន...។

៤.២ បំណិនអាជីពងាយ ត្រូវបានបង្រៀនដល់អ្នកសិក្សាទាំងអស់នៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលជាកម្មវិធីសិក្សានៅចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ មានកាត់ដេរ អ៊ុតសក់ កាត់សក់ ដាំដំណាំ ចិញ្ចឹមសត្វ លក់ដូរ ជួសជុលកង់ ម៉ូតូ ធ្វើឧបករណ៍កសិកម្ម ធ្វើឧបករណ៍ប្រើប្រាស់ ត្បាញ ឆ្លាក់ សំអាងការ ភ្លេងប្រពៃណី សិល្បៈ របាំ...។

៤.៣ បំណិនវិជ្ជាជីវៈ អាចបង្រៀននៅមធ្យមសិក្សាទុតិយភូមិក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស និងអប់រំក្រៅប្រព័ន្ធ មានទេសចរណ៍ គណនេយ្យ បច្ចេកវិទ្យាទំនាក់ទំនងពតិមាន ការគ្រប់គ្រង...។

៥. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនៃការអប់រំបំណិនជីវិត ផ្អែកលើគោលនយោបាយសំខាន់ ៤ របស់ក្រសួងអប់រំ យុវជន និងកីឡា:

១. សកលកម្មការអប់រំមូលដ្ឋានចំនួន ៩ ឆ្នាំ និងបង្កឱកាសអភិវឌ្ឍអក្ខរកម្ម វិជ្ជាជីវៈ។

២. ទំនើបកម្ម និងកែលំអគុណភាពអប់រំ តាមរយៈការកែទម្រង់ដែលមានប្រសិទ្ធភាព។

៣. ការផ្សារភ្ជាប់ការអប់រំ ការបណ្តុះបណ្តាលទៅនឹងទីផ្សារពលកម្ម និងសង្គម។

៤. ការស្តារ និងអភិវឌ្ឍន៍ការងារយុវជន និងកីឡា។

ឈរលើមូលដ្ឋាននៃគោលនយោបាយទាំង៤ខាងលើនេះ គោលនយោបាយអប់រំបំណិនជីវិត២០០៦ បានផ្តោតទៅលើការអភិវឌ្ឍធនធានមនុស្សអោយមានជំនាញឯកទេស និងសមត្ថភាពដែលអាចឆ្លើយតបនឹងស្ថានភាពសង្គម។ ដូចនេះយុទ្ធសាស្ត្រនៃគោលនយោបាយអប់រំបំណិនជីវិតរួមមាន:

- អភិវឌ្ឍធនធានមនុស្សអោយមានជំនាញបច្ចេកទេស និងចំណេះដឹងឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម តម្រូវការសង្គម មានមនសិការការងារ មានស្មារតីទទួលខុសត្រូវ មានវិន័យសីលធម៌ និងគុណធម៌ល្អប្រសើរ ដើម្បីលើកស្ទួយការអភិវឌ្ឍប្រទេសជាតិ។

- បង្កើនការផ្សារភ្ជាប់កម្មវិធីអក្ខរកម្ម និងការអប់រំជ្ញាជីវៈដើម្បីលើកកំពស់ជំនាញមុខរបរ និងចំណេះដឹងសម្រាប់ការសិក្សាពេញមួយជីវិត។

- បង្កើនសមត្ថភាពច្នៃប្រឌិត និងសហគ្រិនភាពដើម្បីបង្កើនប្រាក់ចំណូល លើកកម្ពស់គុណភាពនៃជីវិតរស់នៅ សំដៅកាត់បន្ថយភាពក្រីក្រ លើកស្ទួយជីវភាពគ្រួសារ និងចូលរួមចំណែកអភិវឌ្ឍសង្គមជាតិ។

- ប្រើធនធាន និងទីប្រឹក្សាដែលមាននៅក្នុងសហគមន៍សម្រាប់អនុវត្តសកម្មភាពបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន។

៦. វិធីសាស្ត្រ

៦.១ គោលនយោបាយនេះពន្យល់ពីរបៀបដែលត្រូវបង្រៀនបំណិនជីវិតនៅក្នុងកម្មវិធីសិក្សា។ អ្នកសិក្សាអាចសិក្សា ទាំងទ្រឹស្តី និងការអនុវត្តដើម្បីបង្កើនគុណភាពនៃការរស់នៅរបស់គេ។

៦.២ ការបង្រៀនបំណិនជីវិតមានប្រសិទ្ធភាពទាមទារអោយ :

- ប្រើគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនដើម្បីបង្ហាញ និងកសាងចំណេះដឹង និងពង្រីកចំណេះដឹងដែលអ្នកសិក្សាមានស្រាប់។

- ជំរុញការសិក្សាបែបសកម្ម ដោយធ្វើការងារជាបុគ្គល ការងារជាដៃគូ ការងារជាក្រុម និងការស្រាវជ្រាវតាមរយៈការអានឯកសារផ្សេងៗ ការធ្វើទស្សនកិច្ចសិក្សា ការពិសោធ ការទស្សនា ទូរទស្សន៍ ...។

- សិក្សាទ្រឹស្តី ដោយផ្សារភ្ជាប់នឹងការអនុវត្ត។

- សិក្សាបែបមិត្តអប់រំមិត្ត ឬកុមារដើម្បីកុមារ។

- ធ្វើការផ្សព្វផ្សាយបំណិនជីវិតតាមមធ្យោបាយផ្សេងៗដូចជា ស្បៃវែកៅ ផ្ទត់ផ្ទាំងរូបភាព បណ្ណាល័យចល័ត... និងធ្វើផែនការអភិវឌ្ឍបំណិនជីវិត ថ្មីៗថែមទៀត។

- មានការសិក្សាបែបសហការអន្តរទំនាក់ទំនង សាលារៀន គ្រួសារ និងសហគមន៍។

- មានការវាយតម្លៃដោយផ្អែកលើការអនុវត្តប្រកបដោយតម្លាភាពដើម្បីជួយអោយការសិក្សាកាន់តែប្រសើរ។

- អនុវត្តការបង្រៀន និងរៀនដោយបញ្ជ្រាបបំណិនទូទៅ បំណិនបុរេវិជ្ជាជីវៈ តាមមុខវិជ្ជា និងមានម៉ោង ដោយឡែកក្នុងកាលវិភាគប្រចាំសប្តាហ៍របស់ថ្នាក់នីមួយៗសម្រាប់បង្រៀនបំណិនជីវិតផ្នែកទ្រឹស្តី និងការអនុវត្ត។

- មានធនធានគ្រប់គ្រាន់ (ធនធានមនុស្ស និងសំភារៈ) សម្រាប់ដំណើរការក្នុងពេលអនុវត្ត ។

- មានកម្មវិធីសិក្សាឆ្លើយតបនឹងតម្រូវការ មានប្រធានបទដែលឆ្លើយតបបំផុតទៅនឹងតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកសិក្សា ។

៧. ការណែនាំអនុវត្ត

៧.១ ការអប់រំបំណិនជីវិតនៅសាលារៀនចំណេះទូទៅ

៧.១.១ នៅកម្រិតអប់រំមូលដ្ឋាន កម្មវិធីសិក្សាជាតិបានបញ្ចូលការសិក្សាបំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជា ជីវៈដោយបញ្ជ្រាប និងបញ្ចូលតាមមុខវិជ្ជាសំខាន់ៗទាំងបួន (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម)។ ឧទាហរណ៍ :

- ការងារជាក្រុម
- វិចារគណិតវិទ្យា
- ដំណោះស្រាយបញ្ហា
- ផែនការ ការវិភាគ និងការរៀបចំចាត់ចែង ។

៧.១.២ នៅកម្រិតអប់រំមូលដ្ឋាន គេអាចដឹងសមត្ថភាពរបស់សិស្សផ្នែកបំណិនជីវិតបាន តាមរយៈរង្វាយតំលៃលទ្ធផលសិក្សាធៀបនឹងស្តង់ដានៅថ្នាក់ទី៣ ទី៦ ទី៩ លើមុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម ។

៧.១.៣ ដើម្បីបំពេញកម្មវិធីសិក្សាជាតិអោយកាន់តែមានការផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្ត ព្រមទាំងមានគុណភាព និងប្រសិទ្ធភាព គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥ -២០០៩ បានកំណត់អោយមានកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលមានពី ២-៥ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ដោយផ្តល់ឱកាស និងលទ្ធភាពដល់សាលារៀន ដើម្បីអនុវត្តតាមជម្រើសរបស់ខ្លួន។

៧.១.៤ នៅថ្នាក់ទី១០ សាលារៀនត្រូវបង្រៀនកម្មវិធីសិក្សាបំណិនជីវិតតាមទំរង់ពីរ គឺកម្មវិធីសិក្សាជាតិ និងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដូចនៅកំរិតអប់រំមូលដ្ឋានដែរ។

៧.១.៥ នៅថ្នាក់ទី១១ និង ១២ សាលារៀនត្រូវបង្រៀនកម្មវិធីសិក្សាបំណិនជីវិតតាមទំរង់ពីរ គឺកម្មវិធីសិក្សាជាតិ និងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើសដែលជាមុខវិជ្ជាដែលសិស្សអាចជ្រើសរើស ឬ មិនជ្រើសរើស។

៧.២ ការអប់រំបំណិនជីវិតនៅសាលារៀនក្រៅប្រព័ន្ធ

៧.២.១ កម្មវិធីអក្សរកម្មវិជ្ជាជីវៈ អនុវត្តចំពោះប្រជាជន ដែលមានអាយុពី ១៥ឆ្នាំឡើងទៅ ដោយបានបញ្ចប់បំណិនទូទៅ និងបំណិនបុរេវិជ្ជាជីវៈក្នុងមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ។

៧.២.២ កម្មវិធីបឋមសិក្សាអប់រំក្រៅប្រព័ន្ធ អនុវត្តចំពោះកុមារក្រៅសាលារៀន ដែលមានអាយុពី៦ ដល់ ១៤ ឆ្នាំ ដោយមានម៉ោងសម្រាប់អនុវត្តកម្មវិធីអប់រំបំណិនជីវិតទូទៅ បំណិនបុរេវិជ្ជាជីវៈ បំណិនអាជីពងាយ និងបំណិនវិជ្ជាជីវៈ។

៧.២.៣ កម្មវិធីអប់រំបន្ត

- **កម្មវិធីក្រោយអក្ខរកម្ម** មានទិសដៅទប់ស្កាត់គ្រោះភ្លេចអក្សរ។ កម្មវិធីនេះបានបញ្ជាបបំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជាជីវៈក្នុងខ្លឹមសារនៃកម្មវិធី។

- **កម្មវិធីសមមូល** ជាកម្មវិធីដែលមានតម្លៃប្រហាក់ប្រហែលទៅនឹងកម្មវិធីសិក្សាចំណេះទូទៅ។ ខ្លឹមសារនៃកម្មវិធីនេះបានបញ្ចូលកម្មវិធីអប់រំវិជ្ជាជីវៈឬមុខរបរ និងមានបញ្ជាបបំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជាជីវៈ។

- **កម្មវិធីបង្កើនប្រាក់ចំណូល** មានគោលបំណងលើកកម្ពស់គុណភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់រូបអោយបានប្រសើរ។ ក្នុងកម្មវិធីនេះមានខ្លឹមសារផ្នែកវិជ្ជាជីវៈ ហើយត្រូវអនុវត្តដោយផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលសិក្សាសហគមន៍។

- **កម្មវិធីអប់រំគ្រួសារដើម្បីអភិវឌ្ឍកុមារតូច** មានបញ្ចូលបំណិនជីវិតទូទៅផ្នែកការថែរក្សា គាំពារកុមារតូច ហើយត្រូវអនុវត្តដោយផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលសិក្សាសហគមន៍។ កម្មវិធីនេះមានម៉ោងដោយឡែកសម្រាប់អនុវត្ត។

៧.២.៤ គ្រប់កម្មវិធីសិក្សាអប់រំក្រៅប្រព័ន្ធទាំងអស់ត្រូវអនុវត្តនៅតាមមជ្ឈមណ្ឌលសិក្សាហគមន៍។

៧.៣ ការទទួលខុសត្រូវ ការចូលរួម និងកិច្ចសហការ

៧.៣.១ ក្រសួងអប់រំ យុវជន និងកីឡានឹងផ្តល់ការគាំទ្រដល់កម្មវិធីនេះដូចជា កំណត់ស្តង់ដាកម្មវិធីសិក្សាថ្មី ពង្រឹងសមត្ថភាព ចំណេះដឹង វិធីសាស្ត្រដល់គ្រូបង្រៀន តាមដានត្រួតពិនិត្យ ការបង្រៀនបំណិនជីវិត ផ្តល់គំរូម៉ូឌុលបំណិនជីវិត ជាពិសេសលើកទឹកចិត្តសាលារៀន ដែលជួបការលំបាក និងសាលារៀននៅតំបន់ដាច់ស្រយាល ដើម្បីអោយកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានមានដំណើរការជាជំហានៗតាមលទ្ធភាព។

៧.៣.២ រដ្ឋត្រូវធានាបណ្តុះបណ្តាលគ្រូបង្រៀន កសាងសាលារៀនបន្ថែម ដើម្បីបំពេញតម្រូវការ និងការឈានទៅសម្រេចគោលនយោបាយនេះ។

៧.៣.៣ សាលារៀនត្រូវរួមចំណែកទទួលខុសត្រូវ និងស្វែងរកមូលនិធិ អ្នកជំនាញ ព្រមទាំងការបំពាក់សម្ភារបរិក្ខារសម្រាប់អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដោយសហការជាដៃគូជាមួយមាតាបិតាសិស្ស ព្រះសង្ឃ សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងអាជ្ញាធរដែនដី។

៧.៣.៤ គ្រូបង្រៀន បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល មាតាបិតា សមាជិកសហគមន៍ ឬការសហការគ្នារវាងអ្នកទាំងនោះ អាចបង្រៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋានបាន។

៧.៣.៥ គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នា តាំងពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ជាពិសេសតាមសាលារៀនក្នុង និងក្រៅប្រព័ន្ធអប់រំផ្តាល់ ត្រូវចូលរួមទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយអប់រំបំណិនជីវិត ២០០៦ អោយមានប្រសិទ្ធភាព។

៧.៣.៦ សហគមន៍មូលដ្ឋានចូលរួមសហការជិតស្និទ្ធជាមួយសាលារៀន សំដៅធ្វើអោយការអនុវត្តកម្មវិធីបំណិនជីវិតកាន់តែប្រសើរឡើងដើម្បីធានាថា កម្មវិធីសិក្សានៅសាលារៀនមានការផ្សារភ្ជាប់ទៅនឹងសហគមន៍មូលដ្ឋាន។

៧.៣.៧ អង្គការក្រៅរដ្ឋាភិបាលអាចផ្តល់កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានក្នុងសាលារៀនចំណេះទូទៅបានដោយ:

- បង្រៀនក្នុងរបាយម៉ោងដែលមានសម្រាប់តែកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (ពី ២ ទៅ៥ ម៉ោងសិក្សាក្នុងមួយសប្តាហ៍)។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ទីរអប់រំ យុវជន និងកីឡា។

អត្ថាធិប្បាយ

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា គោលនយោបាយអប់រំបំណិនជីវិតនឹងផ្តល់ចំណេះដឹង និងចំណេះធ្វើដើម្បីបង្កើនគុណភាពការរស់នៅ និងដើម្បីកសាងធនធានមនុស្សអោយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការលើកកំពស់ជីវភាពពិសេសក្នុងការកាត់បន្ថយភាពឥតការងារធ្វើ ។

ក្រសួងអប់រំ យុវជន និងកីឡា សូមអោយគ្រប់អង្គការជំនាញជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ អនុវត្តគោលនយោបាយនេះអោយមានប្រសិទ្ធភាពដោយឈរលើមូលដ្ឋាននៃខ្លឹមសារដែលបានចែងក្នុងផ្នែកនីមួយៗ ។

ក្រសួងសង្ឃឹមថា បណ្តាអង្គការជាតិ-អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធនឹងបន្តចូលរួមលើកកំពស់គុណភាពអប់រំអោយកាន់តែល្អប្រសើរ ។

ក្រសួងអប់រំ យុវជន និងកីឡា ប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយអប់រំបំណិនជីវិត ២០០៦ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី 25 ខែ សីហា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ភុល ជេង









ឧបត្ថម្ភថវិកាដោយ

unicef